អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

ថ្ងៃទី១៨ ខែធ្នូ ឆ្នាំ ២០១៥

# ការិយាល័យសហចៅក្រមស៊ើបអង្កេត
OFFICE OF THE CO-INVESTIGATING JUDGES
BUREAU DES CO-JUGES D'INSTRUCTION

## ការបិទកិច្ចស៊ើបសួរប្រឆាំង អ៊ឹម ចែម
## នៅក្នុងសំណុំរឿង ០០៤/២០-១១-២០០៨/អ.វ.ត.ក/ក.ស.ច.ស

នៅថ្ងៃនេះ សហចៅក្រមស៊ើបអង្កេត បានជូនដំណឹងភាគីទាំងអស់ថា សហចៅក្រមស៊ើបអង្កេត យល់ឃើញថា កិច្ចស៊ើបសួរប្រឆាំង អ៊ឹម ចែម នៅក្នុងសំណុំរឿង០០៤ បានបញ្ចប់ហើយ។

កិច្ចស៊ើបសួរប្រឆាំង អ៊ឹម ចែម បានធ្វើឡើងបន្ទាប់ពីទទួលបានដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទី ៣ ដែលសហព្រះរាជអាជ្ញាអន្តរជាតិ បានដាក់នៅថ្ងៃទី៩ ខែ កញ្ញា ឆ្នាំ ២០០៩។ បន្ទាប់មក វិសាលភាពនៃកិច្ចស៊ើបសួរ ត្រូវបានពង្រីកតាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម ដែលសហព្រះរាជអាជ្ញាអន្តរជាតិ បានដាក់នៅថ្ងៃទី១៨ ខែ កក្កដា ឆ្នាំ ២០១១ នៅថ្ងៃទី២៤ ខែ មេសា ឆ្នាំ ២០១៤ នៅថ្ងៃទី៥ ខែ សីហា ឆ្នាំ ២០១៥ និងនៅថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ ២០១៥។

សេចក្តីជូនដំណឹងនៅថ្ងៃនេះ គឺជាការបិទកិច្ចស៊ើបសួរដែលបានធ្វើឡើងអស់រយៈពេលជាង ៦ ឆ្នាំ លើ អ៊ឹម ចែម ទាក់ទងនឹងឧក្រិដ្ឋកម្មដែលបានចោទថា បានប្រព្រឹត្តឡើងរវាងថ្ងៃទី ១៧ ខែមេសា ឆ្នាំ ១៩៧៥ ដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩។ កិច្ចស៊ើបសួរប្រឆាំង អោ អាន និង យឹម ទិត្យ នៅក្នុងសំណុំរឿង ០០៤ នៅតែបន្តបើកការស៊ើបអង្កេត។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានដាក់ អោ អាន ឲ្យស្ថិតក្រោមការពិនិត្យនៅថ្ងៃទី២៧ ខែមីនា ឆ្នាំ ២០១៥ និងបានដាក់ យឹម ទិត្យ ឲ្យស្ថិតក្រោមការពិនិត្យនៅថ្ងៃទី៩ ខែធ្នូ ឆ្នាំ ២០១៥។